# III. ការងារបណ្ដាក្រសួង
## ពីស្ដីការរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### សេចក្ដីជូនដំណឹង

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៣

### សេចក្ដីជូនដំណឹង លេខ ០១៧ សហវ.សជណ ស្ដីពីការលក់ លតាប័ត្រ ( Vignette ) សំរាប់រថយន្តដែលកំពុងចរាចរក្នុងប្រទេស

* * *

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់រថយន្តដែលកំពុងចរាចរនៅក្នុងប្រទេសអោយបានជ្រាបថា ដើម្បីចាត់ចែងការផ្ដល់សិទ្ធិអោយរថយន្តគ្រប់ប្រភេទធ្វើចរាចរដោយពេញច្បាប់ និង ការប្រមូលពន្ធពន្ធអោយត្រឹមត្រូវយុត្តិធម៌ផងនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដោយសហការជាមួយក្រសួងសាធារណការ និង ដឹកជញ្ជូន នឹងដាក់លក់លតាប័ត្រ ( Vignette ) សំរាប់រថយន្តដែលកំពុងចរាចរក្នុងប្រទេសទៅតាមរូបភាពដូចខាងក្រោមនេះ ។

I - ចាប់ពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៣ រហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៤

ក- ចំពោះរថយន្តទេសចរណ៍ដែលមានលិខិតសំគាល់យន្ត ( Carte grise ) ត្រឹមត្រូវផ្ដល់ដោយ ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវទៅដាក់ពាក្យសុំទិញលតាប័ត្រ ( Vignette ) នៅក្រសួងសាធារណការ និង ដឹកជញ្ជូន ( ផ្នែកផ្ដល់ផ្លាកយានយន្ត ) ។ ការរៀបចំលក់លតាប័ត្រ ( Vignette ) នេះនឹងចាត់ចែងដោយមន្ត្រីពន្ធ និង រដ្ឋាករនិងមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ។ កាលបើពិនិត្យឃើញថា រថយន្តទាំងនោះបានបង់ពន្ធពន្ធរួចហើយ ម្ចាស់រថយន្តត្រូវទិញលតាប័ត្រមួយសន្លឹកដែលតំលៃ ១២.០០០ រៀល ដើម្បីជាការបញ្ជាក់ថា រថយន្តនោះបានបង់ពន្ធពន្ធរួចហើយ ។ ប៉ុន្តែកាលបើពិនិត្យឃើញថា រថយន្ត ណាមួយពុំទាន់បានបង់ពន្ធពន្ធនៅឡើយនោះ គឺម្ចាស់រថយន្តត្រូវទិញលតាប័ត្រមួយសន្លឹកដែលតំលៃតាមបែប អនុគ្រោះដូចមានកំណត់ក្នុងតារាងលេខ ១ ភ្ជាប់ជាមួយសេចក្ដីជូនដំណឹងនេះ ។

ថ្លៃលតាប័ត្រដែលម្ចាស់ រថយន្តត្រូវទិញក្នុងករណីនេះ គឺជំនួសពន្ធគយដែលមិនទាន់បានបង់នៅពេលរថយន្តត្រូវនាំចូលមកក្នុងប្រទេស ។

ខ- ចំពោះរថយន្តទេសចរណ៍ដែលពុំទាន់មានលិខិតសំគាល់យានយន្ត ( Carte grise ) ត្រឹមត្រូវផ្តល់ដោយក្រសួងសាធារណការ និង ដឹកជញ្ជូនទេនោះ ត្រូវទិញលតាប័ត្រមួយសន្លឹក ដែលគិតថ្លៃតាមការកំណត់ក្នុងតារាងលេខ ២ ភ្ជាប់ជាមួយសេចក្តីជូនដំណឹងនេះ ។ ថ្លៃលតាប័ត្រដែលម្ចាស់រថយន្តត្រូវទិញក្នុងករណី ចុងក្រោយនេះកំណត់ដោយគិតរួមទាំងពន្ធគយ ៥០ ٪ និង អាករប្រើប្រាស់ ៤ ٪ ជាធម្មតាដូចរថយន្ត ដែលទើបនាំចូលមកក្នុងប្រទេស ។

គ- ចំពោះរថយន្ត សំរាប់ដឹកជញ្ជូនទំនិញ ដឹកអ្នកដំណើរ ការលក់លតាប័ត្រ ទៅអោយម្ចាស់រថយន្តទាំងនេះត្រូវប្រព្រឹត្តទៅដូចដែលបានចែងសំរាប់រថយន្តទេសចរណ៍ដែរ លើកលែងតែថ្លៃលតាប័ត្រ គឺត្រូវកំណត់តាម តារាងលេខ ៣ ( សំរាប់រថយន្ត ដែលមានលិខិតសំគាល់យានយន្តរួចហើយ ) និង តាម តារាងលេខ ៤ ( សំរាប់យានយន្ត ដែលមិនទាន់មានលិខិតសំគាល់យានយន្តនៅឡើយ ) ។ ការគិតថ្លៃលក់លតាប័ត្រខុសគ្នាពីរថយន្តទេសចរណ៍នេះ ដោយសារថា រថយន្តទាំងនោះ ត្រូវបានកំណត់អោយបង់ពន្ធគយ តែ ១៥ ٪ និង អាករប្រើប្រាស់ ៤ ٪ តែប៉ុណ្ណោះ ។

ក្នុងករណីទាំងអស់ខាងលើនេះ លតាប័ត្របិទនៅផ្នែកខាងក្នុងនៃកញ្ចក់រថយន្ត ជ្រុងខាងស្តាំដោយមន្ត្រីគយភ្នាម ១ ។

II - ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ រហូតដល់ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ម្ចាស់ រថយន្តទាំងឡាយដែលមិនបានរួសរាន់មកទិញលតាប័ត្រតាមកាលកំណត់ដំបូងក្នុងរយៈពេលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៤ នឹងត្រូវពិន័យ ១០ ٪ លើថ្លៃលតាប័ត្រដែលត្រូវទិញ ។

III - ចាប់ពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩៤ នេះតទៅ បើរថយន្តណាមិនមានបិទលតាប័ត្រ នៅលើកញ្ចក់រថយន្តទេនោះ អាជ្ញាធរមានសមត្ថកិច្ចនឹងចាត់ទុកថារថយន្តនោះគ្មានសិទ្ធិធ្វើចរាចរទេ ។ ដូច្នេះ កងកំលាំងនគរបាល អាចឃាត់រថយន្តទាំងនោះបាននៅក្នុងពេលកំពុងធ្វើចរាចរ ដើម្បីអោយម្ចាស់រថយន្ត ទាំងនោះមកបង់ពន្ធនិងពិន័យតាមច្បាប់រដ្ឋកំណត់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

សម រង្ស៊ី

**តារាងលេខ១: ថ្លៃគោលគិតពន្ធសម្រាប់អនុគ្រោះ**
**ចំពោះរថយន្តទេសចរណ៍ដែលមានផ្លាកលេខត្រឹមត្រូវផ្តល់ដោយ**
**ក្រសួងសាធារណការនិង ដឹកជញ្ជូន ប៉ុន្តែពុំបានបង់ពន្ធនាំចូល**

ឯកតាគិត :. ដុល្លារអាមេរិក

| c.c | 1980 | 1981 | 1982 | 1983 | 1984 | 1985 | 1986 | 1987 | 1988 | 1989 | 1990 | 1991 | 1992 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ដល់ 900 | 100 | 150 | 200 | 250 | 325 | 425 | 500 | 600 | 700 | 800 | 900 | 1.0[illegible] | 1.200 |
| 901 ដល់ 1.100 | 150 | 200 | 250 | 325 | 425 | 500 | 600 | 700 | 800 | 950 | 1.075 | 1.200 | 1.300 |
| 1.100 ដល់ 1.300 | 200 | 250 | 300 | 350 | 500 | 575 | 675 | 800 | 950 | 1.075 | 1.200 | 1.300 | 1.425 |
| 1.301 ដល់ 1.500 | 250 | 300 | 350 | 425 | 550 | 675 | 750 | 950 | 1.075 | 1.200 | 1.375 | 1.500 | 1.625 |
| 1.501 ដល់ 1.700 | 300 | 375 | 425 | 500 | 700 | 800 | 925 | 1.050 | 1.200 | 1.400 | 1.550 | 1.675 | 1.825 |
| 1.701 ដល់ 1.900 | 400 | 425 | 500 | 600 | 800 | 900 | 1.025 | 1.175 | 1.300 | 1.500 | 1.625 | 1.800 | 1.950 |
| 1.901 ដល់ 2.100 | 450 | 500 | 600 | 700 | 900 | 1.000 | 1.150 | 1.275 | 1.425 | 1.625 | 1.775 | 1.925 | 2.075 |
| 2.101 ដល់ 2.300 | 550 | 625 | 700 | 800 | 1.000 | 1.125 | 1.275 | 1.400 | 1.625 | 1.700 | 1.900 | 2.050 | 2.175 |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2.301 ដល់ 2.500 | 650 | 725 | 800 | 900 | 1.125 | 1.250 | 1.400 | 1.500 | 1.650 | 1.875 | 2.000 | 2.150 | 2.300 |
| 2.501 ដល់ 2.700 | 750 | 825 | 900 | 1.000 | 1.200 | 1.350 | 1.500 | 1.625 | 1.750 | 2.000 | 2.125 | 2.275 | 2.400 |
| 2.701 ដល់ 2.900 | 850 | 925 | 1.000 | 1.100 | 1.350 | 1.450 | 1.625 | 1.750 | 1.875 | 2.125 | 2.250 | 2.400 | 2.550 |
| 2.901 ដល់ 3.100 | 950 | 1.000 | 1.100 | 1.200 | 1.450 | 1.575 | 1.700 | 1.850 | 2.300 | 2.250 | 2.375 | 2.500 | 2.650 |
| 3.101 ដល់ 3.300 | 1.050 | 1.125 | 1.200 | 1.300 | 1.575 | 1.700 | 1.825 | 1.950 | 2.100 | 2.300 | 2.475 | 2.625 | 2.775 |
| 3.301 ដល់ 3.500 | 1.150 | 1.225 | 1.300 | 1.400 | 1.700 | 1.800 | 1.925 | 2.075 | 2.200 | 2.475 | 2.625 | 2.750 | 2.900 |
| 3.501 ដល់ 3.700 | 1.250 | 1.325 | 1.400 | 1.500 | 1.800 | 1.900 | 2.050 | 2.175 | 2.325 | 2.600 | 2.750 | 2.875 | 3.000 |

ថ្លៃលតាប័ត្រចំពោះរថយន្តដែលមានលើសពី 370 cc គឺបន្ថែម 150 $ us ក្នុងមួយប្រឡង់ 200 cc

**តារាងលេខ ២ : ថ្លៃពន្ធកាតព្វកិច្ច ចំពោះរថយន្តទេសចរណ៍ដែលផ្លាស់ប្តូរកម្មសិទ្ធិ**

ឯកតាគិត : ដុល្លារអាមេរិក

| C.C. | 1980 | 1981 | 1982 | 1983 | 1984 | 1985 | 1986 | 1987 | 1988 | 1989 | 1990 | 1991 | 1992 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ដល់ 900 | 200 | 300 | 400 | 500 | 650 | 850 | 1.000 | 1.200 | 1.400 | 1.600 | 1.900 | 2.150 | 2.400 |
| 901 ដល់ 1.100 | 300 | 400 | 500 | 650 | 850 | 1.000 | 1.200 | 1.400 | 1.600 | 1.900 | 2.150 | 2.400 | 2.600 |
| 1.100 ដល់ 1.300 | 400 | 450 | 600 | 700 | 1.000 | 1.150 | 1.350 | 1.600 | 1.900 | 2.150 | 2.400 | 2.600 | 2.850 |
| 1.301 ដល់ 1.500 | 500 | 600 | 700 | 850 | 1.100 | 1.350 | 1.500 | 1.900 | 2.150 | 2.500 | 2.750 | 3.000 | 3.250 |
| 1.501 ដល់ 1.700 | 600 | 750 | 850 | 1.000 | 1.400 | 1.600 | 1.850 | 2.100 | 2.400 | 2.800 | 3.100 | 3.350 | 3.650 |
| 1.701 ដល់ 1.900 | 800 | 850 | 1.000 | 1.200 | 1.600 | 1.800 | 2.050 | 2.350 | 2.600 | 3.000 | 3.250 | 3.600 | 3.900 |
| 1.901 ដល់ 2.100 | 900 | 1.000 | 1.200 | 1.400 | 1.800 | 2.000 | 2.300 | 2.550 | 2.850 | 3.250 | 3.550 | 3.850 | 4.150 |
| 2.101 ដល់ 2.300 | 1.100 | 1.250 | 1.400 | 1.600 | 2.000 | 2.250 | 2.550 | 2.800 | 3.250 | 3.700 | 3.800 | 4.100 | 4.350 |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2.301 ដល់ 2.500 | 1.300 | 1.450 | 1.600 | 1.800 | 2.250 | 2.500 | 2.800 | 3.000 | 3.300 | 3.750 | 4.000 | 4.300 | 4.600 |
| 2.501 ដល់ 2.700 | 1.500 | 1.650 | 1.800 | 2.000 | 2.500 | 2.700 | 3.000 | 3.250 | 3.500 | 4.000 | 4.250 | 4.550 | 4.800 |
| 2.701 ដល់ 2.900 | 1.700 | 1.850 | 2.000 | 2.200 | 2.700 | 2.900 | 3.250 | 3.500 | 3.700 | 4.250 | 4.500 | 4.800 | 5.100 |
| 2.901 ដល់ 3.100 | 1.900 | 2.000 | 2.200 | 2.400 | 2.900 | 3.150 | 3.400 | 3.700 | 4.000 | 4.500 | 4.750 | 5.000 | 5.300 |
| 3.101 ដល់ 3.300 | 2.100 | 2.250 | 2.400 | 2.600 | 3.150 | 3.400 | 3.650 | 3.900 | 4.200 | 4.700 | 4.950 | 5.250 | 5.550 |
| 3.301 ដល់ 3.500 | 2.300 | 2.450 | 2.600 | 2.800 | 3.400 | 3.600 | 3.850 | 4.150 | 4.400 | 4.950 | 5.250 | 5.500 | 5.800 |
| 3.501 ដល់ 3.700 | 2.500 | 2.650 | 2.800 | 3.000 | 3.600 | 3.800 | 4.100 | 4.650 | 4.600 | 5.200 | 5.500 | 5.750 | 6.000 |

ថ្លៃលក់បំរុងចំពោះរថយន្តដែលមានលើសពី 3700cc គឺបន្ថែម 500$ US ក្នុងមួយប្រឡង 200cc

តារាងលេខ ៣ : ថ្លៃលក់ប័ណ្ណពន្ធកាតលេខ អនុវត្ត
ចំពោះយានយន្តដឹកជញ្ជូន ដឹកអ្នកដំណើរ ដែលមានផ្លាកលេខក្រុមហ៊ុន ផ្តល់ដោយ
ក្រសួងសាធារណការនិងដឹកជញ្ជូន

ឯកតាគិត : ដុល្លារអាមេរិក

| C.C | 1980 | 1981 | 1982 | 1983 | 1984 | 1985 | 1986 | 1987 | 1988 | 1989 | 1990 | 1991 | 1992 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ដល់ 1.700 | 150 | 190 | 215 | 250 | 350 | 400 | 465 | 525 | 600 | 700 | 775 | 840 | 915 |
| 1.701 ដល់ 1.900 | 200 | 215 | 250 | 300 | 400 | 450 | 515 | 590 | 650 | 750 | 815 | 900 | 975 |
| 1.901 ដល់ 2.100 | 225 | 250 | 300 | 350 | 450 | 500 | 575 | 640 | 715 | 815 | 950 | 965 | 1.040 |
| 2.101 ដល់ 2.300 | 275 | 315 | 350 | 400 | 500 | 565 | 640 | 700 | 815 | 850 | 950 | 1.025 | 1.090 |
| 2.301 ដល់ 2.500 | 325 | 365 | 400 | 450 | 565 | 625 | 700 | 750 | 825 | 940 | 1.000 | 1.075 | 1.150 |
| 2.501 ដល់ 2.700 | 375 | 415 | 450 | 500 | 600 | 675 | 750 | 815 | 875 | 1.000 | 1.065 | 1.148 | 1.200 |
| 2.701 ដល់ 4.700 | 425 | 465 | 500 | 550 | 675 | 725 | 815 | 875 | 940 | 1.065 | 1.125 | 1.200 | 1.275 |
| 4.701 ដល់ 6.700 | 475 | 500 | 550 | 600 | 725 | 790 | 850 | 925 | 1.000 | 1.125 | 1.190 | 1.250 | 1.325 |
| 6.701 ដល់ 8.700 | 525 | 565 | 600 | 650 | 790 | 850 | 915 | 975 | 1.050 | 1.150 | 1.240 | 1.315 | 1.390 |
| 8.701 ដល់ 10.700 | 575 | 615 | 650 | 700 | 850 | 900 | 965 | 1.040 | 1.100 | 1.238 | 1.315 | 1.375 | 1.450 |
| 10.701 ដល់ 12.700 | 625 | 665 | 700 | 750 | 900 | 950 | 1.025 | 1.090 | 1.165 | 1.300 | 1.375 | 1.440 | 1.500 |

ថ្លៃលក់ប័ណ្ណពន្ធកាតសម្រាប់យានយន្តមានលើសពី 12700cc គិតថែម 150$ ចំពោះរាល់ 2000cc

## តារាងលេខ ៤ : ថ្លៃលក់ប័ណ្ណប្រចាំឆ្នាំ

### រថយន្តដឹកជញ្ជូន រថយន្តដឹកអ្នកដំណើរ ដែលទើបនាំចូលតាមផ្លូវច្បាប់

ឯកតាគិត: ដុល្លារអាមេរិក

| C.C | 1980 | 1981 | 1982 | 1983 | 1984 | 1985 | 1986 | 1987 | 1988 | 1989 | 1990 | 1991 | 1992 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តិចជាង 1.700 | 240 | 300 | 340 | 400 | 560 | 640 | 740 | 840 | 960 | 1.120 | 1.240 | 1.340 | 1.460 |
| 1.701 ដល់ 1.900 | 320 | 340 | 400 | 480 | 640 | 720 | 820 | 940 | 1.040 | 1.200 | 1.300 | 1.440 | 1.560 |
| 1.901 ដល់ 2.100 | 360 | 400 | 480 | 560 | 720 | 800 | 920 | 1.020 | 1.140 | 1.300 | 1.420 | 1.540 | 1.660 |
| 2.101 ដល់ 2.300 | 440 | 500 | 560 | 640 | 800 | 900 | 1.020 | 1.120 | 1.300 | 1.400 | 1.520 | 1.640 | 1.740 |
| 2.301 ដល់ 2.500 | 520 | 580 | 640 | 720 | 900 | 1.000 | 1.120 | 1.200 | 1.320 | 1.500 | 1.600 | 1.720 | 1.840 |
| 2.501 ដល់ 2.700 | 600 | 660 | 720 | 800 | 1.000 | 1.180 | 1.200 | 1.300 | 1.400 | 1.600 | 1.700 | 1.820 | 1.920 |
| 2.701 ដល់ 4.700 | 680 | 740 | 800 | 880 | 1.080 | 1.160 | 1.300 | 1.400 | 1.480 | 1.700 | 1.800 | 1.920 | 2.040 |
| 4.701 ដល់ 6.700 | 760 | 800 | 880 | 960 | 1.160 | 1.260 | 1.360 | 1.480 | 1.600 | 1.800 | 1.900 | 2.000 | 2.120 |
| 6.701 ដល់ 8.700 | 840 | 900 | 960 | 1.040 | 1.260 | 1.360 | 1.460 | 1.560 | 1.680 | 1.880 | 1.980 | 2.100 | 2.220 |
| 8.701 ដល់ 10.700 | 920 | 980 | 1.040 | 1.120 | 1.360 | 1.440 | 1.540 | 1.660 | 1.760 | 1.980 | 2.100 | 2.200 | 2.320 |
| 10.701 ដល់ 12.700 | 1.000 | 1.060 | 1.120 | 1.200 | 1.440 | 1.520 | 1.640 | 1.740 | 1.860 | 2.080 | 2.200 | 2.300 | 2.400 |

ថ្លៃតាមប្រភេទរថយន្តដែលមានលើសពី 12700cc ត្រូវបន្ថែម 100$ US ក្នុងមួយប្រឡង់ 2000cc